# ករណីសិក្សាស្តីពីឧបករណ៍មិនបង្កទំនាស់

## <u>គម្រោងសហគមន៍នេសាទ អេ អែហ្វ អែស ស៊ី</u>
## <u>និង ជម្លោះនេសាទក្នុងឆកសមុទ្រកំពង់សោម</u>

## ទិដ្ឋភាពទូទៅ

នៅដើមទសវត្សរ៍ឆ្នាំ ២០០០ គណៈកម្មាធិការសេវាកម្មមិត្តភាពអាមេរិក (AFSC) បានចាប់ផ្តើមគម្រោងសហគមន៍នេសាទក្នុងស្រុកស្រែអំបិល ខេត្តកោះកុង នៅភាគខាងជើងនៃឆកសមុទ្រកំពង់សោម។ សហគមន៍នេសាទចំនួន២ ត្រូវបានបង្កើតឡើងក្នុងស្រុកស្រែអំបិល គឺមួយនៅក្នុង ឃុំជីខក្រោម និង មួយទៀតនៅក្នុង ឃុំជ្រោយស្វាយ។ ក្នុងឆ្នាំ ២០០៤ អំពើហិង្សារវាងសហគមន៍នេសាទទាំងពីរត្រូវបានផ្ទុះឡើង ផ្ទះរបស់ពួកគេត្រូវបានលួចប្លន់ និងដុតបំផ្លាញ ហើយការិយាល័យកណ្តាលរបស់សហគមន៍នេសាទ ដែលគាំទ្រដោយ (AFSC) ត្រូវបានដុតបំផ្លាញចោលខ្ទេចខ្ទី។

***សម្គាល់៖** ករណីសិក្សានេះត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១៧ ពោលគឺ ១៣ឆ្នាំ បន្ទាប់ពីហេតុការណ៍នេះបានកើតឡើង ដូចនេះការពិពណ៌នាប្រហែលជាមិនអាចរៀបរាប់អស់ពីហេតុការណ៍ជាក់ស្តែងដែលបានកើតឡើង។ អ្នកសរសេរ សូមអភ័យទោសទុកជាមុនសម្រាប់ចំណុចខ្វះខាតដែលកើតមានឡើង ហើយទោះបីជាយ៉ាងណាយើងសង្ឃឹមថា ករណីសិក្សានេះពិតជាចូលរួមចំណែកជួយដល់ការស្វែងយល់កាន់តែប្រសើរពី **ឧបករណ៍មិនបង្កទំនាស់**[1] ។*

## សាវតា




- នៅដើមទសវត្សរ៍ទី៩០ ការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងស្រុកស្រែអំបិលនៅមានកម្រិតនៅឡើយ ក្នុងនោះការគ្រប់គ្រងតំបន់ព្រៃឈើដោយពួកខ្មែរក្រហមបានបន្តរហូតដល់ឆ្នាំ ១៩៩៦។ ការកាប់ឈើខុសច្បាប់មានការរីករាលដាលរហូតដល់ឆ្នាំ ១៩៩៩ ទើបត្រូវបានបង្ក្រាប។
- ប្រជានេសាទនៅស្រុកស្រែអំបិល បានប្រើប្រាស់ឧបករណ៍នេសាទតាមបែបប្រពៃណី ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩។ ប្រជាពលរដ្ឋមួយចំនួនទៀត បានធ្វើស្រែចម្ការ ចិញ្ចឹមសត្វ កាប់ឈើខុសច្បាប់ និងជួញដូរសត្វព្រៃខុសច្បាប់។
- ក្រោយពីរដ្ឋាភិបាលបានសន្យាចំពោះជីវភាពរស់នៅរបស់អ្នកនេសាទ អ្នកចំណូលថ្មីបានចូលមកដល់ស្ទឹងហាវ ស្ថិតនៅភាគខាងកើតនៃឆកសមុទ្រកំពង់សោម នៅចន្លោះឆ្នាំ១៩៨៤ និង ១៩៨៧ ។ ពួកគេបានទិញកប៉ាល់នេសាទ និងកូនទូកវែងៗជាច្រើន។ ឆ្នាំ ១៩៨៧ ច្បាប់ជលផល ត្រូវបានបង្កើតឡើង ដែលធ្វើឲ្យការនេសាទរបស់ពួកគេនៅក្នុងតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោមក្លាយជាការនេសាទខុសច្បាប់។ ប៉ុន្តែពួកគេមិនមានជម្រើសផ្សេងទៀតក្នុងការចិញ្ចឹមជីវិតឡើយ។
- ច្បាប់ជលផល ឆ្នាំ ១៩៨៧ មិនបានរាប់បញ្ចូលបទប្បញ្ញត្តិសហគមន៍នេសាទទេ
- ទោះបីជាយ៉ាងណា រដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់សហគមន៍នេសាទ ហើយនៅដើមទសវត្សរ៍ ២០០០ ច្បាប់ស្តីពីសហគមន៍នេសាទត្រូវបានពង្រាង[2]
- ក្រោយឆ្នាំ ១៩៩៩ អ្នកចំណូលថ្មីជាច្រើនបានចូលមកដល់ស្ទឹងហាវ ដើម្បីធ្វើការនេសាទខុសច្បាប់។

---

[1] ករណីសិក្សានេះ ត្រូវបានពិពណ៌នាផងដែរក្នុង: គម្រោងរៀនសូត្ររួមគ្នារបស់ CDA “ឧបករណ៍មិនបង្កទំនាស់នៅកម្ពុជា” មេសា ២០១០ ទំព័រ ១៣

http://cdacollaborative.org/wordpress/wp-content/uploads/2016/02/Do-No-Harm-in-Cambodia.pdf

[2] អនុក្រិតស្តីពីសហគមន៍នេសាទត្រូវបានអនុម័តនៅ ខែ មិថុនា ឆ្នាំ ២០០៥ ហើយច្បាប់ជលផលថ្មីត្រូវបានប្រកាសឲ្យប្រើនៅ ខែ ឧសភា ឆ្នាំ ២០០៦

- ប៉ុន្តែក្នុងទសវត្សរ៍ឆ្នាំ ២០០០ នាយកដ្ឋានជលផល ត្រូវបានបង្កើតឡើង ដើម្បីធ្វើការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនៅក្នុងវិស័យជលផល ដោយធ្វើការរួមជាមួយអាជ្ញាធរខេត្ត និងស្រុក។

## ទំនាស់សហគមន៍នេសាទ

ទំនាស់ជលផលបានចាប់ផ្តើមនៅឆ្នាំ១៩៨៩ ។ កប៉ាល់នេសាទ បានអូសសំណាញ់របស់ពួកគេនៅតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោម ដោយរំលោភលើច្បាប់ជលផល ឆ្នាំ ១៩៨៧។ កប៉ាល់នេសាទភាគច្រើន មកពីស្ទឹងហាវក្នុងខេត្តព្រះសីហនុ និងមាននាវិកកម្ពុជាផងដែរ។ និងមានកប៉ាល់នេសាទផ្សេងទៀតមកពីប្រទេសថៃ និង វៀតណាម។ នៅពេលដែល កប៉ាល់នេសាទបានចូលមកដល់ អ្នកនេសាទក្នុងមូលដ្ឋាន នៅស្រុកស្រែអំបិលបានវាយបកវិញ ហើយជារឿយៗមានការលួចត្រីពីសំណាញ់ អ្នកកប៉ាល់នេសាទ។ ក្រុមនាវិកក្នុងកប៉ាល់នេសាទ បានតបតវិញ។ នៅចន្លោះឆ្នាំ ១៩៨៩ និង ២០០២ ក្រុមនាវិកកប៉ាល់នេសាទ បានសម្លាប់អ្នកនេសាទចំនួន ២២ នាក់នៅតំបន់នោះ[3]។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ ២០០០ ដោយមានការពង្រឹងការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងតំបន់ ទំនាស់ជលផលបានថយចុះ។

យ៉ាងណាក៏ដោយនៅឆ្នាំ ២០០៤ អំពើហឹង្សាថ្មីរវាងក្រុមអ្នកនេសាទបានផ្ទុះឡើង។ ក្រុមនាវិកកប៉ាល់នេសាទមកពីស្ទឹងហាវ បានចូលលួចប្លន់ ដុតបំផ្លាញផ្ទះសម្បែង និងការិយាល័យកណ្តាលសហគមន៍នេសាទ នៅឃុំជីខក្រោម ដែលគាំទ្រដោយ AFSC ត្រូវបានដុតបំផ្លាញរាបដល់ដី។

**ទិដ្ឋភាពនៃទំនាស់រួមមាន៖**

- ជាទូទៅអាជ្ញាធរបានចាប់ខ្លួនអ្នកនេសាទតូចតាច ប៉ុន្តែមិនបានចាប់ខ្លួនកប៉ាល់នេសាទធំៗនោះទេ
- នៅពេលកប៉ាល់នេសាទធំៗ ធ្វើនេសាទខុសច្បាប់ អ្នកនេសាទតូចតាចបានរឹបអូសឧបករណ៍នេសាទរបស់ពួកគេ
- នាវិកកប៉ាល់នេសាទ បានឆ្លើយតបដោយហិង្សា ដោយបានវាយប្រហារទៅលើអ្នកនេសាទតូចតាច និងបំផ្លាញឧបករណ៍នេសាទរបស់ពួកគេ។
- ពាក្យចចាមអារ៉ាម (ឧទា៖ ស្តីអំពីអ្នកនេសាទស្រែអំបិល បានចាប់ជម្រិតអ្នកនេសាទស្ទឹងហាវ) នាំឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ។
- អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រដល់សហគមន៍នៅស្ទឹងហាវមានការយល់ឃើញ និង ទស្សនទានស្តីពីសិទ្ធិមនុស្ស ខុសពីការយល់ឃើញ និងទស្សនទានរបស់ AFSC ស្តីពីការការចិញ្ចឹមជីវិតប្រកបដោយចេរភាព។ ពួកគេបានឮរឿងរ៉ាវអំពីអ្នកនេសាទស្រែអំបិល ពីអ្នកនេសាទស្ទឹងហាវ ខុសពីអ្វីដែលបុគ្គលិករបស់ AFSC បានឮ។ ដូច្នេះ អង្គការមិនមែនរដ្ឋាភិបាលរកឃើញថា វាមានការលំបាកណាស់ក្នុងការធ្វើការរួមគ្នា
- ទោះបីជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានផ្សាភ្ជាប់យ៉ាងល្អ និងមានការគោរពយ៉ាងខ្លាំងពីសំណាក់សហគមន៍ ហើយពួកគេមានបំណងបង្កើនទំនាក់ទំនងរវាងសហគមន៍នេសាទទាំងពីរ
- អ្នកចំណូលថ្មីមិនសូវយកចិត្តទុកដាក់លើការថែរក្សាធនធានក្នុងស្រុក ដូចអ្នករស់នៅយូរអង្វែងទេ
- ក្រុមអ្នកនេសាទដែលប្រជែងគ្នា បានកំណត់អត្តសញ្ញាណសហគមន៍របស់ពួកគេដោយខ្លួនឯង ហើយពួកគេមានទំនាក់ទំនងតិចតួចបំផុតរវាងក្រុម និងក្រុម។
- ផ្ទះសម្បែងរបស់សហគមន៍នេសាទ គឺជានិមិត្តរូបនៃអំណាចរបស់សហគមន៍នេសាទ និងជាគោលដៅសម្រាប់ការវាយប្រហារ
- ទោះបីជាមានទំនាស់ក៏ដោយ អ្នកនេសាទទាំងអស់នៅជុំវិញឆកកំពង់សោម មានចំណាប់អារម្មណ៍រួមគ្នាលើនិរន្តរភាពនៃការនេសាទ "ប្រសិនបើត្រីបាត់បង់អស់ អ្នកទាំងអស់គ្នានឹងរងគ្រោះ"
- រដ្ឋាបាលខេត្តកោះកុង និងព្រះសីហនុ មានឆន្ទៈប្រមូលអ្នកពាក់ព័ន្ធមកពិភាក្សារួមគ្នា

---

[3] កាសែតភ្នំពេញប៉ុស្តិ៍ "ការបោះឆ្នោតដោយសម្ងាត់សម្រាប់ជលផលខេត្តកោះកុង" ១៨ កក្កដា ២០០៣

http://www.phnompenhpost.com/national/election-bait-koh-kong-fisheries

# គម្រោង AFSC

គោលដៅរបស់គម្រោង AFSC ក្នុងស្រុកស្រែអំបិលគឺ " **ប្រជាពលរដ្ឋមានភាពអាស្រ័យលើខ្លួនឯង ឈានទៅរកការចិញ្ចឹមជីវិតប្រកបដោយចេរភាព និងបរិស្ថានធម្មជាតិត្រូវបានគ្រប់គ្រងប្រកបដោយចេរភាព និងសមធម៌** "។ គម្រោងត្រូវបានអនុវត្តដោយអ្នកគ្រប់គ្រងកម្មវិធី ដែលត្រូវរាយការណ៍ទៅតំណាងប្រទេសប្រចាំនៅទីក្រុងភ្នំពេញ។ មូលនិធិទទួលបានមកពីម្ចាស់ជំនួយ (**អឺរ៉ុប និងអាមេរិក**)។ គម្រោងបានចាប់ផ្ដើមក្នុងឆ្នាំ **១៩៩៧**។ ផ្នែកជលផលបានកើតឡើងក្នុងឆ្នាំ ២០០១។ សហគមន៍នេសាទចំនួន ២ ត្រូវបានបង្កើតឡើងក្នុងស្រុកស្រែអំបិល មួយនៅក្នុង **ឃុំជីខក្រោម** និង មួយទៀតនៅក្នុង **ឃុំជ្រោយស្វាយ**។ ក្រុមគោលដៅ គឺជាគ្រួសារក្រីក្ររស់នៅក្នុងស្រុកស្រែអំបិល នៃខេត្តកោះកុង រួមបញ្ចូលទាំងគ្រួសារដែលពឹងផ្អែកទៅលើការនេសាទសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។

ធនធានមនុស្សទាំងអស់របស់គម្រោងក្នុងឆ្នាំ២០០៤ សុទ្ធតែជាជនជាតិខ្មែរ ក្នុងនោះមួយចំនួនមកពីតំបន់គោលដៅរបស់គម្រោង ប៉ុន្តែបុគ្គលិកភាគច្រើនមកពីភ្នំពេញ ឬ ខេត្តផ្សេងៗ។

AFSC ជួយអ្នកនេសាទប្រើប្រាស់វិធីនេសាទបែបប្រពៃណីដែលធ្វើឡើងដោយខ្លួនឯង។ ក្នុងឆ្នាំ ២០០៣ សហគមន៍នេសាទឃុំជីខក្រោម ទទួលបានការទទួលស្គាល់ពីអាជ្ញាធរខេត្ត។ សហគមន៍នេសាទឃុំជ្រោយស្វាយ ទទួលបានការទទួលស្គាល់ក្នុងឆ្នាំ ២០០៦។ សហគមន៍នេសាទទាំងពីរ ក៏ទទួលបានការគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការផាកពិន័យ ឬ ចាប់ខ្លួន និងឃុំឃាំងអ្នកនេសាទកប៉ាល់ធំៗណា ដែលបានប្រើប្រាស់សំណាញ់ និងឧបករណ៍នេសាទខុសច្បាប់នៅក្នុងតំបន់នេសាទដែលបានកំណត់។

សកម្មភាពកម្មវិធីក្នុងឃុំជីខក្រោម និងឃុំជ្រោយស្វាយមាន៖

- ផ្ដល់ការបណ្ដុះបណ្ដាលទៅសហគមន៍នេសាទស្ដីពីច្បាប់ជលផល (ដោយមន្ត្រីជលផល)
- ផ្ដល់ការបណ្ដុះបណ្ដាលទៅសហគមន៍នេសាទស្ដីពីការគ្រប់គ្រងធនធានធម្មជាតិ និងសហគមន៍នេសាទ
- ផ្ដល់ការបណ្ដុះបណ្ដាលទៅសហគមន៍នេសាទស្ដីពីសកម្មភាពអហិង្សា (ដោយអង្គការខ្មែរអហិង្សា)
- ផ្ដល់អាវការពារ មួកការពារសុវត្ថិភាព និងផ្ដល់អាយកូមសម្រាប់ការល្បាតរបស់សហគមន៍នេសាទ
- ភ្ជាប់សហគមន៍នេសាទទាំងពីរក្រុមទៅបណ្ដាញ NGO ថ្នាក់ជាតិ
- ទស្សនកិច្ចសិក្សាទៅគម្រោងសហគមន៍នេសាទផ្សេងទៀតក្នុងប្រទេសកម្ពុជា

AFSC មិនបានផ្ដល់ជំនួយអ្វីដល់សហគមន៍នេសាទដែលនៅក្រៅតំបន់គោលដៅរបស់ពួកគេឡើយ។

ក្រោយមក AFSC បានវិភាគអ្វីដែលបានកើតឡើង ដោយប្រើប្រាស់ជំនាញ និងបទពិសោធន៍របស់ខ្លួន ក្នុងនាមជាអង្គការកសាងសន្តិភាពមួយ ដោយបានព្យាយាមរៀបចំគម្រោងរបស់ខ្លួនឡើងវិញ ដើម្បីពង្រឹងសមត្ថភាពមូលដ្ឋានសម្រាប់សន្តិភាពនិងកាត់បន្ថយប្រភពនៃភាពតានតឹង។

AFSC បានដឹងថា ពួកគេបានធ្វើការជាមួយគ្នាភាគីទំនាស់តែម្ខាង គឺអ្នកនេសាទក្នុងស្រុកស្រែអំបិល ខណៈដែលតំបន់ដែលមានទំនាស់ គឺឆកសមុទ្រកំពង់សោមទាំងមូល។ ដើម្បីនិរន្តរភាពធនធានធម្មជាតិនៃឆកសមុទ្រ និងកាត់បន្ថយទំនាស់ ឆកសមុទ្រទាំងមូល វាគួរតែត្រូវបានរាប់បញ្ចូល ទាំងអ្នកនេសាទស្ទឹងហាវ ជាក្រុមគោលដៅ។

AFSC បានអនុវត្តតាមគំនិតមួយចំនួនខាងក្រោម ដើម្បីធ្វើឲ្យកត្តាបែកបាក់ចុះខ្សោយ និងពង្រឹងពង្រឹងកត្តាផ្សាភ្ជាប់ឲ្យកាន់តែរឹងមាំ ហើយជម្រើសទាំងអស់នេះត្រូវបានយកមកប្រើប្រាស់។

| ជម្រើសកម្មវិធី៖ |
| --- |
| 1. ពង្រីកតំបន់គោលដៅគម្រោង AFSC ដើម្បីបញ្ចូលសហគមន៍នេសាទទាំងអស់នៅជុំវិញឆកសមុទ្រ<br>2. គាំទ្រដល់ការបង្កើតសហគមន៍នេសាទនៅគ្រប់សហគមន៍ទាំងអស់<br>3. ផ្តល់ធនធានដល់សហគមន៍នេសាទទាំងអស់ស្មើៗគ្នា<br>4. រៀបចំកិច្ចប្រជុំគ្រប់អ្នកពាក់ព័ន្ធទាំងអស់ជាមួយអ្នកនេសាទមកពីសហគមន៍ទាំងអស់ អភិបាលខេត្ត មន្ត្រីជលផល ក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីដោះស្រាយទំនាស់ជលផល<br>5. ផ្តល់ជំនួយបន្ថែមដល់មន្ត្រីជលផល ដើម្បីកែលម្អការអនុវត្តរបស់ពួកគេ<br>6. ជួយសហគមន៍ ដើម្បីបង្កើតសញ្ញាសម្គាល់ព្រំដែននេសាទកាន់តែច្បាស់ សម្រាប់តំបន់សហគមន៍នេសាទ<br>7. បណ្តុះបណ្តាលបុគ្គលិកក្នុងការវិភាគទំនាស់ និងការឆ្លើយតប ព្រមទាំងរបៀបទទួលស្គាល់សមត្ថភាពមូលដ្ឋានសម្រាប់សន្តិភាព<br>8. រៀបចំបណ្តាញសហគមន៍នេសាទ ដើម្បីកសាងកិច្ចសហប្រតិបត្តិការលើការងារការពារធនធានធម្មជាតិនៅឆកសមុទ្រកំពង់សោម<br>9. រៀបចំប្រព័ន្ធទំនាក់ទំនង ដោយប្រើប្រាស់អាយកូម រវាងសមាជិកបណ្តាញសហគមន៍នេសាទ ដើម្បីឆ្លើយតបទៅនឹងពាក្យចចាមអារាម និងរាយការណ៍ពីការចាប់ខ្លួនសម្រាប់ការនេសាទខុសច្បាប់<br>10. ជំរុញឲ្យមានការចរចារដោយផ្ទាល់រវាងសហគមន៍នេសាទស្ទឹងហាវ និងសហគមន៍នេសាទជីខក្រោម (ស្រុកស្រែអំបិល) ដែលរៀបចំដោយបណ្តាញតស៊ូមតិសហគមន៍នេសាទថ្នាក់ជាតិ<br>11. រៀបចំកសកម្មភាពស្រាវជ្រាវ ដោយមានការចូលរួមពីសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីប្រវត្តិនៃសហគមន៍នេសាទផ្សេងៗគ្នា ដើម្បីបង្កើនការយល់ដឹង និងស្គាល់គ្នាទៅវិញទៅមក<br>12. គាំទ្រដល់ការបង្កើតជម្រើសផ្សេងៗនៃការចិញ្ចឹមជីវិតនៅគ្រប់សហគមន៍ទាំងអស់ ដើម្បីកាត់បន្ថយការពឹងផ្អែកលើវិស័យជលផល (ការនេសាទ)<br>13. រកម្ចាស់ជំនួយបន្ថែមដើម្បីគាំទ្រសកម្មភាពខាងលើ |

# សេចក្តីបញ្ចប់

ជាក់ស្តែង ការរៀបចំឡើងវិញនៃគម្រោង ***ទទួលបានជោគជ័យ*** ក្នុងការជួយកាត់បន្ថយទំនាស់ហិង្សា ផ្នែកជលផល និងការការពារធនធានធម្មជាតិឱ្យបានប្រសើរជាងមុន។ ទំនាស់ហិង្សា នៅតែកើតមានឡើងម្តងម្កាល ប៉ុន្តែមានតិចតួចជាងពីមុន។

នៅឆ្នាំ ២០០៥ បុគ្គលិក AFSC បានប្រមូលផ្តុំអ្នកពាក់ព័ន្ធមកពីទីតាំងទាំងពីរ គឺ**ស្ទឹងហាវ និង ស្រែអំបិល** ដើម្បីបង្កើនការយល់ពីគ្នាទៅវិញទៅមក និង កិច្ចសហប្រតិបត្តិការ។ ដំណើរការដោះស្រាយទំនាស់បានចាប់ផ្តើម។ AFSC បានចាប់ផ្តើមផ្តល់ការគាំទ្រដល់សហគមន៍ស្ទឹងហាវ ស្តីពីសហគមន៍នេសាទ និងសកម្មភាពចិញ្ចឹមជីវិតផ្សេងៗទៀត។

នៅឆ្នាំ ២០០៧ AFSC បានពង្រីកសកម្មភាពគម្រោងរបស់ខ្លួនទៅភាគខាងលិចនៃឆកសមុទ្រកំពង់សោម នៅ ថ្មស និងតាមែក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែម ក្នុងចំណោមអ្នកនេសាទពីគ្រប់ទិសទីនៃឆកសមុទ្រកំពង់សោម។ សហគមន៍នេសាទទាំងអស់បានរួមគ្នាបង្កើតជាបណ្តាញមួយឡើង។ គម្រោងស្រាវជ្រាវតាមបែបចូលរួម បានស្វែងយល់ពីរឿងរ៉ាវរបស់អ្នកនេសាទពីកន្លែងផ្សេងៗគ្នា និងការបង្កើតការយោគយល់គ្នា និង បង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀត។